# របាយការណ៍ប្រចាំត្រមាសទី៣

(ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣)

## ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (លានរៀល) | ត្រីមាសទី៣ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
|---|---|---|
| ទ្រព្យសកម្មសរុប | ៤.៣៤៧.៨០៣ | ៤.០៤៣.៥៣០ |
| បំណុលសរុប | ៣.៤៦៨.៧៧០ | ៣.២៣៨.០៣៨ |
| មូលធនសរុប | ៨៧៩.០៣២ | ៨០៥.៤៩២ |
| **លទ្ធផលហិរញ្ញវត្ថុ (លានរៀល)** | **ត្រីមាសទី៣ឆ្នាំ២០២៣** | **ត្រីមាសទី៣ឆ្នាំ២០២២** |
| ចំណូលសរុប | ៩៧.៧៣៥ | ៨២.៣៨២ |
| ចំណេញ(ខាត)មុនបង់ពន្ធ | ៣៧.១៣៩ | ៣១.៣៩៩ |
| ចំណេញ(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ | ២៨.២៨១ | ២៥.២០៦ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ២៧.៧០៣ | ២៩.០២៤ |
| **អនុបាតហិរញ្ញវត្ថុ(%)** | **ត្រីមាសទី៣ឆ្នាំ២០២៣** | **ឆ្នាំ២០២២** |
| អនុបាតសាធនភាព ❶ | ១៩,៧២ | ២១,៨១ |
| អនុបាតបំណុលធៀបនឹងមូលធន | ៣៩៤,៦១ | ៤០២,០០ |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព ❶ | ១១០,៥៥ | ១២៧,៤៦ |
| អនុបាតឥណទានមិនដំណើរការ ❷ | ៥,៤៤ | ៤,៦១ |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ១០៤,៤១ | ១០៥,០៣ |
| **អនុបាតផលចំណេញ(%)** | **ត្រីមាសទី៣ឆ្នាំ២០២៣** | **ត្រីមាសទី៣ឆ្នាំ២០២២** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (ROA) ❸ | ២,៥៣ | ២,៨៣ |
| អនុបាតចំណេញធៀបនឹងមូលធន (ROE) ❹ | ១២,៥០ | ១៤,៦៦ |
| អនុបាតលទ្ធភាពបង់ប្រាក់ | ៧៧២,៨៥ | ៩៣៥,៦៦ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | មិនមាន | មិនមាន |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | មិនមាន | មិនមាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | មិនមាន | មិនមាន |

សំគាល់ :

❶: អនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយធនាគារជាតិនៃកម្ពុជា

❷: ឥណទានមិនដំណើរការអនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយធនាគារជាតិនៃកម្ពុជាចំណាត់ថ្នាក់សំវិធានធន ២០% - ១០០%

❸: អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម : លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ / ទ្រព្យសកម្មសរុប

❹: អនុបាតចំណេញធៀបនឹងមូលធន : លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ / មូលធនសរុប

*) លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទទាបជាងចំណេញ(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ ដោយសារលម្អៀងពីការប្តូររូបិយប័ណ្ណ។

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប









# សមាសភាពក្រុមប្រឹក្សាភិបាល



**YIM, Yong Taick**

ប្រធានក្រុមប្រឹក្សាភិបាល



**SIM, Sang Ton**

អភិបាលប្រតិបត្តិ



**BANG, Keuk Bong**

អភិបាលប្រតិបត្តិ



**HONG, Jee Soo**

អភិបាលឯករាជ្យ



**LEE, Myunsang**

អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ក្នុងនាមតំណាងឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ក្នុងការបង្ហាញពីលទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ ដោយអនុវត្តតាមតម្រូវការរបស់ និយ័តករមូលបត្រកម្ពុជា (ន.ម.ក)។

ស្ថានភាពសេដ្ឋកិច្ច និងទីផ្សារហិរញ្ញវត្ថុមិនមានភាពអំណោយផលនោះទេ ដែលវិបត្តិនេះភាគច្រើនកើតចេញពីសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន និងកំណើនអត្រាអតិផរណានៅលើសកលលោក ដែលបង្អាក់ដល់ការនាំចេញរបស់កម្ពុជា ព្រមទាំងការធ្លាក់ចុះសេដ្ឋកិច្ចសកល ដែលនាំអោយការវិនិយោគបរទេសមកកម្ពុជាមានតិចជាងមុន។

ដើម្បីយកឈ្នះស្ថានភាពដ៏លំបាកនេះ និងបន្តរីកចម្រើនទៅមុខទៀត វិស័យធនាគារបានបន្តដើរតួនាទីជាប្រភពហិរញ្ញប្បទានដ៏សំខាន់ក្នុងការផ្តល់ថាមពល ទៅដល់វិស័យសំខាន់ៗនៃសេដ្ឋកិច្ច ដែលកំពុងងើបឡើងវិញនិងកំពុងត្រូវការធនធានហិរញ្ញវត្ថុ ដើម្បីបន្តជំរុញសកម្មភាពសេដ្ឋកិច្ច។ ក្នុងដំណាក់កាលនៃការស្តារសេដ្ឋកិច្ចឡើងវិញ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានផ្តល់ឥណទានទៅកាន់វិស័យឯកជន ជាពិសេសសហគ្រាសធុនតូចនិងមធ្យម ដែលនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើតឱកាសការងារ បង្កើនប្រាក់ចំណូលរបស់ប្រជាជន សំដៅដល់ការជំរុញកំណើនសេដ្ឋកិច្ចជាតិ។

ក្នុងនាមតំណាងឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគទុនិកក្រុមប្រឹក្សាភិបាល គណៈប្រតិបត្តិទាំងអស់នៃធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក សម្រាប់ការណែនាំ និងភាពជាអ្នកដឹកនាំ, បុគ្គលិករបស់យើងទាំងអស់សម្រាប់ការចូលរួមចំណែក និងការប្តេជ្ញាចិត្ត, អតិថិជនរបស់យើងទាំងអស់សម្រាប់ទំនុកចិត្តរបស់ពួកគេមកលើធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ជាពិសេស ធនាគារជាតិ នៃកម្ពុជា (NBC) និងនិយ័តករមូលបត្រកម្ពុជា (SERC) សម្រាប់ដំបូន្មាន និងការគាំទ្រ។

ជាចុងក្រោយ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ជាមួយនឹងការបន្តការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែង ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក នឹងបន្តរីកចម្រើន និងមានការអនុវត្តល្អបំផុតនៅឆ្នាំ២០២៣ ជាមួយនឹងសមិទ្ធផលនៃគោលដៅផ្សេងបន្ថែមទៀត។

ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣

ហត្ថលេខា និងត្រា

YIM. Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

# មាតិកា

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** ..... 1

**ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប** ..... 2

**សមាសភាពក្រុមប្រឹក្សាភិបាល** ..... 3

**សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល** ..... 4

**ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ** ..... 7

ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ..... 7

ខ. លក្ខណៈនៃធុរកិច្ច ..... 8

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ..... 9

**ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ..... 11

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក ..... 11

ខ. រចនាសម្ព័ន្ធចំណូល ..... 11

**ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ** ..... 12

**ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ..... 13

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ..... 13

ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ..... 15

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ..... 17

ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ..... 17

ង. ផលប៉ះពាល់អតិផរណា ..... 18

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល ..... 18

**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក** ..... 19

# ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក** |
| ជាអក្សរឡាតាំង | **Phnom Penh Commercial Bank Plc.** |
| លេខកូដស្តង់ដារ | KH ២០០០១១១A46 |
| ទីស្នាក់ការ | អគារលេខ២១៧ មហាវិថីនរោត្តម<br>សង្កាត់ទន្លេបាសាក់ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | (+៨៥៥) ២៣ ៩០៩ ៩០៩/(+៨៥៥) ២៣ ៩៩៩ ៥០០ |
| គេហទំព័រ | www.ppcbank.com.kh |
| អ៊ីមែល | info@ppcb.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១៥៧៩៤ ចុះថ្ងៃទី២០ មេសា ២០០៨ |
| លេខអាជ្ញាបណ្ណអាជីវកម្ម | B២៣ ចេញដោយធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៦ ធ្នូ ២០១៩ |
| សេចក្តីសម្រេចអនុញ្ញាតិនិងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៩២/២០ គ.ម.ក./ស.ស.រ ចុះថ្ងៃទី០១កញ្ញា ២០២០ |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូល | លោក Lee Jin Young |

## ខ. លក្ខណៈនៃធុរកិច្ច

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានចាប់ផ្តើមប្រតិបត្តិការធនាគារ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ ដែលមានទីស្នាក់ការកណ្តាលស្ថិតនៅអគារលេខ២១៧ មហាវិថី ព្រះនរោត្តម (ផ្លូវលេខ ៤១) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និងទទួលបានអាជ្ញាបណ្ណពេញលេញជាធនាគារពាណិជ្ជ។ នៅខែកញ្ញា ឆ្នាំ២០១៦ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានស្វាគមន៍សម្រាប់ការចាប់ផ្តើមថ្មីមួយជាមួយភាគទុនិកដ៏រឹងមាំគឺ Jeonbuk Bank Co. Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co. Ltd.). ក្រុមហ៊ុន Apro Financial Co. Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន J&K Capital Co.. Ltd. ដែលស្ថិតនៅក្រោម OK Financial Group) និងក្រុមហ៊ុន JB Woori Capital Co. Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co. Ltd.) ដែលមានមូលដ្ឋានស្ថិតនៅប្រទេសកូរ៉េខាងត្បូង។

នៅពេលដែលយើងបន្តកិច្ចខំប្រឹងប្រែងរបស់យើងទៅមុខទៀត យើងក៏មិនភ្លេចនឹងអបអរសាទរចំពោះភាពជោគជ័យនាពេលកន្លងមក ក្នុងការបំពេញបាននូវតម្រូវការជាច្រើនរបស់អតិថិជនក្នុងផ្នែកសេវាធនាគារ និងខិតខំស្វែងរកវិធីសាស្ត្រនានា ដើម្បីលើកកម្ពស់គុណភាពសេវារបស់យើងគាំទ្រអតិថិជនរបស់យើងទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។ គិតត្រឹមត្រីមាសទី៣ ឆ្នាំ២០២៣ ទ្រព្យសកម្មសរុបរបស់យើងមានចំនួន ១,០៥៥ លានដុល្លារអាមេរិក មាន ២៣ សាខាទូទាំងប្រទេស និង ៦៨ ម៉ាស៊ីនATM និង ២ CRMs កំពុងដំណើរការនៅទូទាំងប្រទេស (ម៉ាស៊ីន ATM និង CRM ផ្សេងទៀតកំពុងត្រូវបានសិក្សាដើម្បីដំឡើងនៅតាមទីតាំងដែលមានសក្តានុពលទូទាំងប្រទេស)។ បន្ថែមពីនោះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក នឹងបន្តធ្វើការផ្តល់ជូនដល់អតិថិជននូវសេវាដែលមានលក្ខណៈងាយស្រួល និងធ្វើការគាំទ្រដោយបណ្តាញឌីជីថល(សេវាធនាគារចល័ត សេវាធនាគារតាមប្រព័ន្ធអ៊ិនធើណែត សេវាផ្ញើសារជូនដំណឹង) ដែលធ្វើឲ្យអតិថិជនកាន់តែមានភាពងាយស្រួលជាមួយនឹងបទពិសោធន៍ធនាគារ។ ក្រៅពីនេះយើងក៏បាននិងកំពុងបន្តបង្កើតផលិតផលនិងសេវាកម្មជាច្រើនទៀតដើម្បីបំពេញតម្រូវការរបស់អតិថិជនដូចជា សេវាទូទាត់ (កាតឥណពន្ធVisa កាតឥណទានVisa សេវាម៉ាស៊ីនឆូតកាត ការទទួលកាតVisaលើម៉ាស៊ីន ATM), ប្រាក់បញ្ញើ (គណនីសន្សំ គណនីចរន្ត គណនីមានកាលកំណត់ គណនីសន្សំថេរ), សេវាសម្ព័ន្ធភាពជាមួយភាគីទី៣

(វីង រដ្ឋករទឹកស្វយ័ត អគ្គីសនីកម្ពុជា បសស អេអឹមខេ ទ្រូម៉ាន់នី បញ្ញើ បាគង ។ល។) សេវាឥណទាន (ឥណទានលំនៅដ្ឋាន ឥណទានរថយន្ត ឥណទានខ្នាតតូចនិងមធ្យម និងឥណទានពាណិជ្ជកម្ម ជាច្រើនទៀត) និងមានផលិតផលជាច្រើនទៀត (KHQR ហិរញ្ញប្បទានពាណិជ្ជកម្ម បើកប្រាក់បៀវត្ស ផ្ទេរប្រាក់ Western Union សេវាប្តូរប្រាក់ ។ល។)។

អតិថិជនអាចធ្វើការទំនាក់ទំនងមកយើងតាមរយៈ live chat ២៤ម៉ោងក្នុងមួយថ្ងៃ និង ៧ថ្ងៃក្នុងមួយសប្តាហ៍ តាមរយៈបណ្តាញ ឌីជីថលទាំងអស់របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក។ ពួកយើងពិតជាផ្តល់តម្លៃដល់អតិថិជនទាំងអស់ និងបន្តធ្វើការអភិវឌ្ឍផលិតផល-សេវា របស់ពួកយើង ដើម្បីបម្រើជូនដល់អតិថិជនឲ្យបានល្អបំផុត។

## គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ក្នុងនាមយើងជាធនាគារដែលផ្តោតលើការផ្តល់ភាពងាយស្រួលដល់អតិថិជន យើងតែងតែព្យាយាមក្នុងការពង្រីកបន្ថែមនូវសកម្មភាពប្រតិបត្តិការអាជីវកម្ម និងនាំមកនូវមធ្យោបាយកាន់តែប្រសើរសម្រាប់អតិថិជនដ៏មានតម្លៃរបស់យើង។

ដូច្នេះនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣, PPCBank បានផ្តល់ជូននូវភាពរីករាយដល់អតិថិជនជាមួយការបញ្ចុះតម្លៃ ៥០% សម្រាប់ការកុម្ម៉ង់អាហារដោយទៅយកផ្ទាល់នៅហាង រៀងរាល់ថ្ងៃពុធ ដោយគ្រាន់តែទូទាត់ជាមួយ PPCBank Visa កាត នៅលើ Foodpanda App ចាប់ពីថ្ងៃដែលផ្សាយដំណឹង រហូតដល់ថ្ងៃទី៣០ ខែ កញ្ញា ឆ្នាំ២០២៣ ឬរហូតដល់អស់ពីស្តុក។

នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣ ជាមួយនឹងមុខងារផ្ញើរប្រាក់ទៅមករវាងប្រទេសកូរ៉េ និងកម្ពុជា ដោយឥតគិតថ្លៃសេវា។ កាន់តែពិសេសសម្រាប់អតិថិជនដែលមានបំណងផ្ញើប្រាក់ទៅកាន់សាច់ញាតិ ឬទូទាត់សេវាកម្មផ្សេងៗនៅប្រទេសកូរ៉េខាងត្បូង។ អតិថិជនអាចផ្ញើរប្រាក់ទៅមកបាន តាមរយៈ PPCBank Mobile App ដោយងាយស្រួល ព្រមទាំងទឹកប្រាក់ចូលក្នុងគណនីរបស់អ្នកទទួលភ្លាមៗ ចំពោះអតិថិជនដែលមានគណនីនៅធនាគារ Jeonbuk Bank។ អតិថិជនអាចរីករាយជាមួយការផ្តល់ជូនពិសេសសម្រាប់ការផ្ទេរប្រាក់បានរហូតដល់ ៥,០០០ ដុល្លារ ដោយឥតគិតថ្លៃរហូតដល់បំណាច់ឆ្នាំ២០២៣។

នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣, PPCBank ផ្តល់ជូននូវការទូទាត់ទំនិញតាមអនឡាញប្រកបដោយទំនុកចិត្ត និងសុវត្ថិភាពតាមរយៈការទូទាត់ដោយប្រើ PPCBank Visa កាត។ ដើម្បីការពារហិរញ្ញវត្ថុរបស់អតិថិជន PPCBank Visa កាត ឥលូវនេះបានបន្ថែមនូវមុខងារការពារសុវត្ថិភាព (3D-Secure) ដែលអតិថិជននឹងទទួលបានលេខកូដផ្ទៀងផ្ទាត់តាមរយៈ PPCBank Mobile ឬ SMS រាល់ពេលទិញទំនិញអនឡាញនៅលើ App ឬ Website ណាមួយ។

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣, PPCBank ផ្តល់ជូននូវការទូទាត់ថ្លៃភាគទានដោយឥតគិតថ្លៃជាមួយ PPCBank Mobile Banking App។ អតិថិជនអាចបង់ភាគទានតាមរយៈ Mobile Banking, smartBiz ឬនៅតាមសាខាណាមួយរបស់ PPCBank យ៉ាងងាយស្រួល រហ័ស និងឥតគិតថ្លៃសេវា។

# ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក

| លទ្ធផលសម្រេចបានសំខាន់ៗ | ត្រីមាសទី៣ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
|---|---|---|
| **ផ្នែកសេវាឥណទាន** | | |
| ចំនួនគណនីឥណទាន | ១០.០០២ | ៨.៨៣៧ |
| ឥណទានដុលសរុប (លានរៀល) | ៣.៤៧២.៩៤០ | ៣.២០២.៩៨២ |
| **ផ្នែកសេវាប្រាក់បញ្ញើ** | | |
| ចំនួនគណនីប្រាក់បញ្ញើ | ១៦៤.៥១០ | ១៤៨.៣៨០ |
| ប្រាក់បញ្ញើសរុប (លានរៀល) | ៣.២២៨.៧៨០ | ២.៩៧៤.១៨៣ |
| **ព័ត៌មានទូទៅ** | | |
| ចំនួនសាខាបើកដំណើការ | ២៣ | ២៣ |
| ចំនួនបុគ្គលិកសរុប | ៤៥១ | ៤៨៥ |
| ចំនួនម៉ាស៊ីន អេធីអឹម | ៧០ | ៧១ |
| ចំនួនម៉ាស៊ីនទូទាត់ | ២២៤ | ២១៥ |

## ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី៣ឆ្នាំ២០២៣ | | ត្រីមាសទី៣ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន (លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៩៤.៣០២ | ៩៦,៤៩ | ៧៨.៩៥៨ | ៩៥,៨៤ |
| ២ | ចំណូលកម្រៃ និងជើងសារ | ៣.៣៤១ | ៣,៤២ | ១.៨៩១ | ២,៣០ |
| ៣ | ចំណូលផ្សេងៗ | ៩២ | ០,០៩ | ១.៥៣៣ | ១,៨៦ |
| **ចំណូលសរុប** | | **៩៧.៧៣៥** | **១០០** | **៨២.៣៨២** | **១០០** |

# ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមមើលឧបសម្ពន្ធរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ។

# ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងវិភាគខាងក្រោមផ្តោតលើលទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារ ភ្នំពេញពាណិជ្ជម.ក (PPCBank)និងក្រុមហ៊ុនបុត្រសម្ព័ន្ធ J&A (Cambodia) Investment Co.. Ltd គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ដែលត្រូវបានត្រួតពិនិត្យដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុរួមត្រូវបានរៀបចំស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ហ.អ.ក) និងអនុលោមទៅតាមបទបញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍ណែនាំផ្សេងៗដែលចេញដោយធនាគារជាតិនៃកម្ពុជា។

## ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ធនាគារភ្នំពេញពាណិជ្ជម.ក មានប្រភពចំណូលចំនួន៣ធំៗគឺ ចំណូលការប្រាក់ ចំណូលពីកម្រៃ និងជើងសារនិងចំណូលផ្សេងៗ។

- ចំណូលការប្រាក់រួមមាន ចំណូលការប្រាក់ពីការផ្តល់ឥណទាន ចំណូលការប្រាក់ពីការដាក់ប្រាក់បញ្ញើរនៅធនាគារ និងចំណូលការប្រាក់បានមកពីមូលបត្រវិនិយោគនានា។
- ចំណូលកម្រៃ និងជើងសាររួមមាន កម្រៃសេវាឥណទាន ចំណូលពីការផ្ទេរប្រាក់ក្នុងស្រុក និងបរទេស ចំណូលពីសេវាប្រាក់បញ្ញើ ចំណូលពីសេវាធានា និង ចំណូលពីប័ណ្ណផ្សេងៗ។
- ចំណូលផ្សេងៗ រួមមាន ចំណូលពីអត្រាប្តូរប្រាក់លើការវិនិយោគ និងចំណូលផ្សេងៗទៀត។

### ២. ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល | ត្រីមាសទី៣ឆ្នាំ២០២៣ | | ត្រីមាសទី៣ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន(លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៩៤.៣០២ | ៩៦,៤៩ | ៧៨.៩៥៨ | ៩៥,៨៤ |
| ២ | ចំណូលកម្រៃ និងជើងសារ | ៣.៣៤១ | ៣,៤២ | ១.៨៩១ | ២,៣០ |
| ៣ | ចំណូលផ្សេងៗ | ៩២ | ០,០៩ | ១.៥៣៣ | ១,៨៦ |
| ចំណូលសរុប | | ៩៧.៧៣៥ | ១០០ | ៨២.៣៨២ | ១០០ |

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ទទួលបានចំណូលភាគច្រើនមកពីការប្រាក់ ដែលមាន ៩៦% នៃប្រាក់ចំណូលសរុបក្នុងត្រីមាសទី៣ ឆ្នាំ២០២៣។

## ៣. ការវិភាគគម្លាតចំណេញដុល

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានរៀបចំរបាយការណ៍លទ្ធផលរួមរបស់ខ្លួនក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីប្រាក់ចំណេញដុល ប៉ុន្តែទម្រង់របាយការណ៍នេះអាចបង្ហាញលើចំណេញការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់ដែលនឹងត្រូវយកមកពិភាក្សានៅក្នុងចំណុចបន្ទាប់ការវិភាគចំណេញ(ខាត) មុនបង់ពន្ធ។

## ៤. ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ

| សង្ខេបនៃរបាយការន៏ចំនេញខាត | ត្រីមាសទី៣ ឆ្នាំ២០២៣ (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២២ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ចំណូលពីការប្រាក់ | ៩៤.៣០២ | ៧៨.៩៥៨ | ១៥.៣៤៤ | ១៩,៤៣ |
| ចំណាយលើការប្រាក់ | (៣៨.៥៦៧) | (២៥.៩២៦) | (១២.៦៤១) | ៤៨,៧៦ |
| **ចំណូលមកពីការប្រាក់សុទ្ធ** | **៥៥.៧៣៥** | **៥៣.០៣២** | **២.៧០២** | **៥,១០** |
| ចំណូលកម្រៃ និងជើងសារ | ៣.៣៤១ | ១.៨៩១ | ១.៤៥០ | ៧៦,៧០ |
| ចំណាយកម្រៃ និងជើងសារ | (១.១៨១) | (៩៩៤) | (១៨៦) | ១៨,៧២ |
| **ចំណូលកម្រៃនិងជើងសារសុទ្ធ** | **២.១៦១** | **៨៩៧** | **១.២៦៤** | **១៤១,០០** |
| ចំណូលប្រតិបត្តិការផ្សេងៗ | ៩២ | ១.៥៣៣ | (១.៤៤១) | (៩៤,០០) |
| ចំណាយបុគ្គលិក | (៨.៥៣២) | (៨.៣៥១) | (១៨១) | ២,១៧ |
| ចំណាយប្រតិបត្តិការ | (៥.៧៦៩) | (៧.៩៦០) | ២.១៩១ | (២៧,៥៣) |
| ចំណាយរំលស់ | (៦.២៥០) | (៦.៨៧៩) | ៦២៩ | (៩,១៥) |
| **ប្រាក់ចំណេញពីប្រតិបត្តិការ** | **៣៧.៤៣៧** | **៣២.២៧២** | **៥.១៦៥** | **១៦,០០** |
| ការខាតបង់លើឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ | (២៩៧) | (៨៧៣) | ៥៧៦ | (៦៥,៩៥) |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **៣៧.១៣៩** | **៣១.៣៩៩** | **៥.៧៤១** | **១៨,២៨** |

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ ប្រាក់ចំណេញមុនបង់ពន្ធមានចំនួន ៣៧.១៣៩លានរៀល (១៨% ច្រើនជាងប្រៀបធៀបទៅនឹងត្រីមាសទី៣ ឆ្នាំ២០២២) ។ ការកើនឡើងនៃប្រាក់ចំណេញគឺដោយសារការកើនឡើងនៃចំណូលការប្រាក់លើឥណទាន។

## ៥. ការវិភាគចំណេញ (ខាត) ក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ត្រីមាសទី៣ ឆ្នាំ២០២៣ (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២២ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ៣៧.១៣៩ | ៣១.៣៩៩ | ៥.៧៤១ | ១៨,២៨ |
| ចំណាយពន្ធលើប្រាក់ចំណូល | (៨.៨៥៨) | (៦.១៩៣) | (២.៦៦៥) | ៤៣,០៤ |
| **ប្រាក់ចំណេញសុទ្ធក្នុងគ្រា** | **២៨.២៨១** | **២៥.២០៦** | **៣.០៧៥** | **១២,២០** |

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ ប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធមានចំនួន ២៨.២៨១លានរៀល ដែលបានកើនឡើង ១២% ប្រៀបធៀបទៅនឹងត្រីមាសទី៣ ឆ្នាំ២០២២ ការកើនឡើងនេះមកពីការប្រែលប្រួលដូចបានបកស្រាយក្នុងចំនុច៤ (ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ)។

## ៦. ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ត្រីមាសទី៣ ឆ្នាំ២០២៣ (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២២ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញសុទ្ធក្នុងគ្រា | ២៨.២៨១ | ២៥.២០៦ | ៣.០៧៥ | ១២,២០ |
| ការខាតលម្អិតផ្សេងៗ | (៥៧៨) | ៣.៨១៨ | (៤.៣៩៦) | (១១៥,១៣) |
| **ប្រាក់ចំណេញលម្អិតសរុប** | **២៧.៧០៣** | **២៩.០២៤** | **(១.៣២០)** | **(៤,៥៥)** |

## ៧. ការវិភាគកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ជាមួយនឹងអត្រាអតិផរណាស្នូលនៅតែខ្ពស់ និងការធ្លាក់ចុះយឺតៗនៅក្នុងប្រទេសសេដ្ឋកិច្ចជឿនលឿនជាច្រើនរួមទាំងវិបត្តិអចលនទ្រព្យនៅក្នុងប្រទេសចិន ធនាគារកណ្តាលអាចនឹងត្រូវរក្សាគោលនយោបាយរូបិយវត្ថុឱ្យកាន់តែតឹងរឹងយូរជាងជាមួយនឹងតម្លៃបច្ចុប្បន្ននៅក្នុងទីផ្សារ។

ដូច្នេះ សកម្មភាពរបស់ធនាគារ អាចនឹងមានផលប៉ះពាល់ខ្លះៗ មកលើប្រតិបត្តិការហិរញ្ញវត្ថុ និងកម្រិតនៃប្រាក់ចំណេញរបស់ធនាគារក្នុងរយៈពេលខ្លីនេះ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ទោះបីជាអតិផរណាស្នូលនៅតែពិបាកបន្ធូបន្ថយក្នុងប្រទេសជាច្រើនក៏ដោយ អ្នកវិនិយោគនៅតែមានក្តីសង្ឃឹមថា ធនាគារកណ្តាលក្នុងប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿននឹងគ្រប់គ្រងដោយការសម្របសម្រួលប្រកបដោយសុទ្ធិនិយម ដោយអនុញ្ញាតឱ្យពួកគេចាប់ផ្តើមកាត់បន្ថយអត្រាការប្រាក់គោលនយោបាយនៅត្រីមាសខាងមុខនេះ។ ជាមួយនឹងការរំពឹងទុកនេះ ធនាគារ PPCBank ក៏បានបន្ថែមសេវាកម្មបន្ថែមទៀត ដើម្បីទាក់ទាញប្រភពមូលនិធិថ្មីៗ ដើម្បីរក្សាកំណើនរបស់ធនាគារ៖

- ផ្តល់សេវាសម្រាប់ការផ្ទេរប្រាក់ភ្លាមៗរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសកូរ៉េខាងត្បូងដោយមិនគិតថ្លៃ។ ឱកាសពិសេសមួយកំពុងត្រូវបានផ្តល់ជូនដល់អតិថិជនរបស់ធនាគារ ដែលអនុញ្ញាតឱ្យពួកគេផ្ទេរប្រាក់ទៅមកសាច់ញាតិរបស់ពួកគេ ឬចូលរួមក្នុងប្រតិបត្តិការទូទាត់ផ្សេងទៀតនៅក្នុងប្រទេសកូរ៉េខាងត្បូង។ អតិថិជនអាចរីករាយជាមួយការផ្តល់ជូនពិសេសរបស់ធនាគារក្នុងការផ្ទេរប្រាក់ដោយមិនគិតថ្លៃនៃចំនួនទឹកប្រាក់ផ្ទេររហូតដល់ ៥.០០០ដុល្លារអាមេរិក ដែលមានប្រសិទ្ធភាពរហូតដល់ចុងឆ្នាំ ២០២៣។
- PPCBank បានណែនាំមុខងារសុវត្ថិភាពថ្មី (3D-Secure) ដើម្បីការពារហិរញ្ញវត្ថុរបស់អតិថិជនដោយប្រើកាតវីសា PPCBank ។ ឥឡូវនេះ រាល់ពេលដែលអតិថិជនធ្វើការទិញទំនិញអនឡាញតាមរយៈកម្មវិធី ឬគេហទំព័រណាមួយ នឹងទទួលបានលេខកូដផ្ទៀងផ្ទាត់តាមរយៈ PPCBank Mobile ឬ SMS។
- ផ្តល់ការទូទាត់វិក្កយបត្រជាមួយកម្មវិធី PPCBank Mobile Banking ដោយមិនគិតថ្លៃ។ អតិថិជនអាចបង់វិភាគទានបានយ៉ាងងាយស្រួល និងមានសុវត្ថិភាពតាមរយៈ Mobile Banking, smartBiz ឬសាខា PPCBank ណាមួយ ដោយមិនគិតថ្លៃសេវា។

### ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនមានផលប៉ះពាល់ដល់ធនាគារឡើយ ។

### ៣. ការវិភាគលើពន្ធ

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនត្រូវមានកាតព្វកិច្ចបង់ពន្ធដូចបានកំណត់ក្នុងបទប្បញ្ញត្តិស្តីពីពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា។

ជាមួយនឹងកាតព្វកិច្ចពន្ធ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានទទួលវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ "**មាស**" ពីអគ្គនាយដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ ២០២២ និង២០២៣។

### ៤. ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

ជាមួយនឹងអតិផរណាស្នូលនៅតែខ្ពស់ និងធ្លាក់ចុះបន្តិចម្តងៗក្នុងប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនជាច្រើន ជាមួយនឹងស្ថានភាពនេះអាចប៉ះពាល់ដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក មានការកើនឡើងនៃចំណូលដែលមានចំណូលការប្រាក់សុទ្ធសរុប ៥៥.៧៣៥លានរៀល ដែលស្មើនឹងការកើនឡើង ៥.១០% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២២។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ស្ថានភាពចំហនៃរូបិយប័ណ្ណបរទេស ត្រូវបានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ជាប្រចាំតាមបទបញ្ញាត្តិ ដើម្បីអាចវាស់វែង និងធានាថាវានឹងមិនធ្វើឲ្យប៉ះពាល់ដល់និរន្តរភាពនៃប្រាក់ចំណេញរបស់ធនាគារ។

ពាក់ព័ន្ធនឹងអត្រាការប្រាក់ធនាគារកំណត់អត្រាការប្រាក់ថេរសម្រាប់ប្រាក់បញ្ញើរ និងប្រាក់កម្ចីរបស់ខ្លួនសម្រាប់ប្រតិបត្តិការអាជីវកម្ម។ ដូច្នេះធនាគារមិនមានទទួលរងហានិភ័យជាសារវន្តទាក់ទងនឹងអត្រាការប្រាក់មកលើលទ្ធផលនៃប្រតិបត្តិការអាជីវកម្មធនាគារនោះទេ ។

ឥទ្ធិពលនៃថ្លៃទំនិញ មិនមានផលប៉ះពាល់មកលើលទ្ធផលប្រតិបត្តិរបស់ធនាគារឡើយ ។

## ង. ផលប៉ះពាល់អតិផរណា

ជាមួយអត្រាអតិផរណាបច្ចុប្បន្ន នឹងមិនមានផលប៉ះពាល់ណាមួយជាសារវន្តមកលើលទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ធនាគារនៅឡើយទេ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល

នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជា បានចេញសេចក្តីជូនដំណឹងពីរ៖

១- ស្តីពី ការកំណត់អត្រាការប្រាក់ថ្មីសម្រាប់ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី (Marginal Lending Facility-MLF) ដែលធនាគារជាតិនៃកម្ពុជានឹងធ្វើការផ្លាស់ប្តូរអត្រាការប្រាក់នៃឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF) ពី ៤% ទៅ ៦% ហើយជាមួយនឹងអត្រាការប្រាក់ថ្មីនេះ គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាចស្នើសុំធ្វើប្រតិបត្តិការបន្តដោយមិនកំណត់ ដែលនឹងត្រូវអនុវត្តចាប់ពីថ្ងៃចន្ទទី២៣ ខែតុលា ឆ្នាំ២០២៣ តទៅ។

២- ធនាគារជាតិនៃកម្ពុជា ក៏បានចេញសេចក្តីជូនដំណឹងផងដែរ ស្តីពី ការផ្លាស់ប្តូរយន្តការប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ឥណប្រតិទាន ៧ថ្ងៃ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់សន្ទនីយភាពរបស់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា នឹងធ្វើការកែសម្រួលថ្ងៃទូទាត់សម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ឥណប្រតិទាន ៧ថ្ងៃ ពីការទូទាត់ (T+2) មកជាការទូទាត់ (T+0) វិញ ដែលនឹងអនុវត្តចាប់ពីថ្ងៃចន្ទទី២៣ ខែតុលា ឆ្នាំ២០២៣ នេះតទៅ។

ចំពោះប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ដែលមានឥណប្រតិទាន ៩១ថ្ងៃ ១៨២ថ្ងៃ និង៣៦៤ថ្ងៃ ធនាគារជាតិនៃកម្ពុជា នឹងរក្សាទុកយន្តការនៃការទូទាត់ (T+2) នៅដដែល។

**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក**

ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣

បានអាន និងឯកភាព

លោក YIM. Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

PPCBank